# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់**

**និងប្រព័ន្ធយុត្តិធម៌**

**អង្គភាពគ្រប់គ្រងគម្រោង**

**លេខៈ**

## របាយការណ៍ស្តីពីសកម្មភាពការងារសរុបចាប់ពី ខែមករា រហូតដល់ ខែកញ្ញា ឆ្នាំ ២០០៥ របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងទិសដៅសម្រាប់អនុវត្តបន្ត

**ស្ថានភាពរួម ៖**

ក្នុងរយៈពេលប្រាំបួនខែដើមឆ្នាំ២០០៥នេះក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌ ដោយមានអង្គភាពសម្រប សម្រួលអចិន្ត្រៃយ៍ ជាអ្នកសម្របសម្រួលដំណើរការប្រចាំថ្ងៃ និងមានអង្គភាពគ្រប់គ្រងគម្រោងជាអង្គភាពប្រតិបត្តិបានដំណើរ ការងាររបស់ខ្លួនស្របតាមបេសកកម្មដែលបានកំណត់ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ហើយសម្រេចបាននូវលទ្ធផលជាក់ស្តែងដូច ខាងក្រោម ៖

## I.ការងារដែលអនុវត្តកន្លងមក ៖

**ក.ការងារកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌**

- **ការងាររដ្ឋបាល ៖**
  - បានធ្វើការប្រជុំមន្ត្រីក្នុងអង្គភាពគ្រប់គ្រងគម្រោង ដើម្បីពង្រឹងវិន័យការងារ និងរៀនសូត្រអំពីការរៀបចំបញ្ជីគម្រោង ( Project Catalogue )
  - បានចូលរួមរៀបចំឯកសារសម្រាប់ផែនការសកម្មភាពអភិបាលកិច្ចលើកទី២ ( Gap II ) ជូនឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
  - បានធ្វើការប្រជុំក្នុងអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ និងអង្គភាពពាក់ពន្ធ័ស្វែងយល់ពីបញ្ហាខ្វះសាលសវនាការ និងបញ្ហាខ្វះមធ្យោបាយបញ្ជូនជនជាប់ចោទចូលសវនាការ
  - បានធ្វើការប្រជុំក្រុមប្រឹក្សា ដើម្បីលើកវិធានការដោះស្រាយបញ្ហាជាបន្ទាន់ចំពោះមុខពាក់ពន្ធ័ដល់អំពើពុករលួយ និងការកកស្ទះសំណុំរឿងនៅក្នុងតុលាការ

- បានចុះស្វែងយល់អំពីស្ថានភាពជាក់ស្តែងនៃតុលាការក្រុងភ្នំពេញដើម្បីលើកគម្រោងបន្ថែមបន្ទប់សវនាការ និងរៀបចំបន្ទប់តម្កល់ឯកសារ
- បានរៀបចំឯកសារស្តីពីកម្មវិធីសកម្មភាពកំណែទម្រង់ច្បាប់ និងតុលាការ និងឯកសារជំនួយស្មារតីសម្រាប់ដាក់ជូនការប្រជុំពេញអង្គនៃគណៈរដ្ឋមន្ត្រី និងកែសម្រួលសារជាថ្មីតាមស្មារតីអង្គប្រជុំពេញអង្គ ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៥
- ប្រជុំវាយតម្លៃលើការងារអនុវត្តកន្លងមកក្នុងត្រីមាសទី១ និងលើកទិសដៅសម្រាប់ត្រីមាសទី២
- ធ្វើសិក្ខាសាលាផ្សព្វផ្សាយកម្មវិធីសកម្មភាពសម្រាប់ការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ នៅសណ្ឋាគារកាំបូឌីយាណា ជូនក្រសួងស្ថាប័នអ្នកអនុវត្តយុទ្ធសាស្ត្រ ថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ ២០០៥
- ប្រជុំជាមួយសង្គមស៊ីវិលផ្សព្វផ្សាយ កម្មវិធីសកម្មភាពសម្រាប់ការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ ថ្ងៃទី ២១ ខែកក្កដា ឆ្នាំ ២០០៥
- ប្រជុំជាមួយប្រទេសផ្តល់ជំនួយ ក្រោមអធិបតីភាពរបស់ ឯកឧត្តម **ស៊ុំ ម៉ានិត** ដើម្បីបង្ហាញពីផែនការសកម្មភាពសម្រាប់អនុវត្តន៍កំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌ កាលពីថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៥
- ផ្ញើជូនក្រសួងពាក់ពន្ធ័នូវឯកសារស្តីពីកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ
- ចូលរួមកិច្ចប្រជុំពិភាក្សាតុមូលស្តីពីកំណែទម្រង់ និងការប្រមើលមើលប្រពន្ធ័យុត្តិធម៌នៅកម្ពុជា នៅសណ្ឋាគារ Sunway ក្រោមអធិបតីភាពឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សុខ អាន** ។
- ចូលរួមប្រជុំជាមួយក្រុមការងារបច្ចេកទេសកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌ ក្រោមអធិបតីភាពឯកឧត្តម **សំ សុខផល** ចំនួន៤លើក
- ចូលរួមប្រជុំបន្ត នៅក្រុមប្រឹក្សាអ្នកច្បាប់ ស្តីពីសេចក្តីព្រាងក្រមនីតិវិធីព្រហ្មទណ្ឌ
- ប្រជុំផ្ទៃក្នុងដើម្បីជម្រុញឱ្យការងាររបស់ក្រុមគម្រោងមានដំណើរការល្អទៅមុខ និងពិភាក្សាលើបញ្ជីគម្រោង ( Project Catalogue, formal Work Plan ) ថ្ងៃទី ១៦-០៩-២០០៥។

**ខ.ការទំនាក់ទំនងជាមួយស្ថាប័នផ្សេងៗ**

- ចូលរួមពិនិត្យសេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ រៀបចំដោយក្រសួងទំនាក់ទំនងជាមួយព្រឹទ្ធសភា រដ្ឋសភា និងអធិការកិច្ច
- ចូលរួមសិក្ខាសាលាស្តីពីទំនាក់ទំនងរវាងក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃ
- ចូលរួមពិភាក្សាជាមួយក្រុមការងារសិក្សាពីប្រធានបទទាក់ទងនឹងច្បាប់ស្តីពីលទ្ធភាពទទួលបាននូវព័ត៌មាន
- ឆ្លើយតប និងសំណូររបស់អគ្គលេខាធិការរងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) លើប្រធានបទទាក់ទងនឹងកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌ ដើម្បីបញ្ចូលក្នុងឯកសារស្តីពីស្ថានភាព និងភាពរីកចំរើនរបស់វិស័យនីមួយៗនៃកំណែទម្រង់របស់រដ្ឋ
- ចូលរួមប្រជុំជាមួយរាជបណ្ឌិតសភាពិនិត្យពិចារណាលើការរៀបចំវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិ

- ជួបប្រជុំជាមួយថ្នាក់ដឹកនាំសាលាភូមិន្ទរដ្ឋបាល ស្វែងយល់ពីគម្រោងបណ្តុះបណ្តាលផ្នែកបច្ចេកវិទ្យាពត៌មាន និង ទំនាក់ទំនង
- បានអញ្ជើញគណៈកម្មការយូនីកូដ ( Unicode ) មកធ្វើបទឧទ្ទេសនាមអំពីការប្រើប្រាស់អក្ខរក្រមខ្មែរក្នុង កុំព្យូទ័រ ( Unicode ) និងចូលរួមជួយពិនិត្យសេចក្តីព្រាងអនុក្រឹត្យស្តីពីការដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវអក្ខរក្រមខ្មែរក្នុង កុំព្យូទ័រ
- ចូលរួមប្រជុំប្រចាំសប្តាហ៍របស់ក្រុមការងារធ្វើវិសោធនកម្មច្បាប់ការងារជាមួយក្រុមប្រឹក្សាអាជ្ញាកណ្តាល
- ចូលរួមសិក្ខាសាលាអន្តរជាតិស្តីពីការធ្វើច្បាប់ប្រឆាំងនឹងអំពើពុករលួយ នៅមហាវិទ្យាល័យបញ្ញាសាស្ត្រចំនួនពីរលើក គឺ នៅថ្ងៃទី ១៤-១៥ ខែកក្កដា ឆ្នាំ ២០០៥ កន្លងទៅថ្មីៗនេះ
- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពីផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ក្រោមអធិបតីភាព ឯកឧត្តម **ឆាយ ថន** នៅសណ្ឋាគារ Inter-continental ចំនួនពីរលើក
- ចូលរួមប្រជុំជាមួយស្ថានទូតបារាំង និងក្រសួងយុត្តិធម៌ ក្រោមអធិបតីភាព ឯកឧត្តម **ហ៊ី សោភា** អំពីការងារ ទាក់ទងនឹងពាក្យបច្ចេកទេសក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ និងបញ្ហាធ្វើច្បាប់ស្តីពី អង្គការចាត់តាំងតុលាការ
- ជួបជាមួយតំណាងខាង AusAid អំពី Logical Framework Approach
- ជួបជាមួយតំណាង UNDP ក្រោមប្រធានបទច្បាប់ប្រឆាំងអំពើពុករលួយក្រោមអធិបតីភាពឯកឧត្តម **សំ សុខផល**
- ជួបប្រជុំជាមួយគណៈប្រតិភូបារាំង ដឹកនាំដោយលោក Patrice Davost នាយកសេវាកម្មយុត្តិធម៌ នៃ ក្រសួងយុត្តិធម៌
- ចូលរួមសិក្ខាសាលាស្តីពីនីតិវិធីជំនុំជម្រះក្តីព្រហ្មទណ្ឌ នៅសណ្ឋាគារសាន់វេ
- ជួបជាមួយក្រសួងយុត្តិធម៌ស្វែងយល់ពីការអនុវត្តយុទ្ធសាស្ត្រកណ្តាប់ដៃដែកក្នុងវិស័យយុត្តិធម៌ និងគម្រោងយុត្តិធម៌ នៅមូលដ្ឋាន
- ជួបពិភាក្សាជាមួយគណៈប្រតិភូក្រសួងការបរទេសដាណឺមាកដឹកនាំដោយលោកស្រី Darriann Riber ដើម្បីស្វែង យល់ដកពិសោធន៍លើសហប្រត្តិបត្តិការ រវាងអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍-អង្គភាពគ្រប់គ្រងគម្រោងនៃក្រុម ប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ឋ័យុត្តិធម៌ និងវិទ្យាស្ថានដាណឺមាកសម្រាប់សិទ្ធិមនុស្សកន្លងមក
- ចូលរួមប្រជុំនៅក្រុមប្រឹក្សាអ្នកច្បាប់ ស្តីពីព្រាងក្រមនីតិវិធីព្រហ្មទណ្ឌ
- ចូលរួមប្រជុំអន្តរក្រសួង ស្តីពីព្រាងក្រមនីតិវិធីព្រហ្មទណ្ឌ
- ចូលរួមប្រជុំជាមួយក្រុមការងារបច្ចេកទេសនៅ CDC ស្តីពីការកំណែទម្រង់រដ្ឋក្រោមអធិបតីភាព ឯកឧត្តម **តាត ឈន់** ថ្ងៃទី ១៥-០៩-២០០៥
- ចូលរួមប្រជុំស្តីពីអភិបាលកិច្ចល្អលើ Gap II ក្រោមអធិបតីភាពឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទីស្តីការ គណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី ២១-០៩-២០០៥ ។

**គ.ការងារសហប្រតិបត្តិការអន្តរជាតិ**

- ចុះស្វែងយល់ជាមួយគណៈប្រតិភូវិទ្យាស្ថានដាណឺម៉ាកសម្រាប់សិទ្ធិមនុស្ស (DIHR) អំពីរដ្ឋបាលតុលាការនៅក្រសួង យុត្តិធម៌ សាលាឧទ្ធរណ៍ និងតុលាការកំពូល

- ជួបជាមួយកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) ដើម្បីពិភាក្សាលើបញ្ហាពុករលួយ និងលើសេចក្តីព្រាងច្បាប់ប្រឆាំងនឹងអំពើពុករលួយ
- ចុះហត្ថលេខាលើកិច្ចព្រមព្រៀងសហប្រតិបត្តិការរវាង វិទ្យាស្ថានដាណឺម៉ាកសម្រាប់សិទ្ធិមនុស្ស (DIHR) និងអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ (PCB) បន្តសម្រាប់ឆ្នាំ២០០៥
- ពិនិត្យរៀបចំរបាយការណ៍ស្តីពីការសិក្សាស្វែងយល់អំពីយន្តការដោះស្រាយវិវាទក្រៅប្រពន្ធ័តុលាការ រៀបចំដោយកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP)
- ជួបជាមួយគណៈប្រតិភូ IMF ស្វែងយល់ពីភាពជឿនលឿននៃកំណែទម្រង់ច្បាប់ និងតុលាការ
- ទទួលជួបជាមួយនឹងស្ថានទូតអង់គ្លេស គណៈប្រតិភូ World Vision ជម្រាបជូនពីកម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- បានអញ្ជើញ CCJAP Expert ដើម្បីបង្រៀនអំពី Monitoring of Evaluation ។
- ចូលរួមសិក្ខាសាលានៅកាំបូឌីយ៉ាណា ស្តីពីកម្មវិធីសម្រាប់យុត្តិធម៌ នៅតំបន់អាស៊ី ប៉ាស៊ីហ្វិក ដែលរៀបចំដោយ UNDP
- ជួបជាមួយ EWMI លើគម្រោងសិក្សាស្រាវជ្រាវ អំពីជំនួយផ្នែកច្បាប់។

## II. សេចក្តីសន្និដ្ឋាន

ក្នុងរយៈពេលដើមឆ្នាំ២០០៥នេះ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌ អង្គភាពគ្រប់គ្រងគម្រោងនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌ បានបំពេញការងារយ៉ាងសកម្ម ហើយសម្រេចបាននូវលទ្ធផលដ៏ប្រសើរសម្រាប់ការអនុវត្តនូវកម្មវិធីកំណែទម្រង់ច្បាប់ និងតុលាការ គឺបានរៀបចំរួចរាល់ជាស្រេចនូវឯកសារកម្មវិធីសកម្មភាព សម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ ដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យ និងសម្រេចឯកភាព ហើយបានធ្វើការផ្សព្វផ្សាយជូនក្រសួងស្ថាប័នពាក់ពន្ធ័អង្គការសង្គមស៊ីវិល និងតំណាងសហគមន៍អ្នកផ្តល់ជំនួយ និងឈានទៅរកការអនុវត្តជាបណ្តើរៗ នូវកម្មវិធីសកម្មភាពនោះទៀតផង។

## III. ទិសដៅសម្រាប់អនុវត្តបន្ត

- បញ្ចប់ការរៀបចំបញ្ជីគម្រោង និងផែនការការងារសម្រាប់ការគ្រប់គ្រងគម្រោងទាំងមូល
- រៀបចំសិក្ខាសាលាធ្វើការផ្សព្វផ្សាយកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការនៅតាមខេត្ត -ក្រុង
- ចុះធ្វើការទំនាក់ទំនង ជាមួយក្រសួងពាក់ពន្ធ័សំខាន់ៗនៃវិស័យយុត្តិធម៌
- បន្តទំនាក់ទំនងជាមួយសហគមន៍អ្នកផ្តល់ជំនួយ ដើម្បីអនុវត្តជាបណ្តើរៗនូវកម្មវិធីសកម្មភាព។

*ធ្វើនៅភ្នំពេញ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៥*

អ្នកធ្វើរបាយការណ៍

**បានឃើញ និងឯកភាព**

ប្រធាន  អ.គ.គ

សេង  វ៉ាន់ដា

ស៊ុយ ម៉ុងលាង